ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........................សហវ.....

*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧*

# របាយការណ៍ស្តីពី
# ការប្រើប្រាស់ឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង ពីរដ្ឋាភិបាលប្រទេសនានា និងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី សម្រាប់ឆមាសទី២ ឆ្នាំ២០១៦

ក្នុងឆមាសទីពីរ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើ*កិច្ចព្រមព្រៀងឥណទានសម្បទាន ចំនួន ១៦ គម្រោង* ជាមួយរដ្ឋាភិបាលបរទេសនានា និងជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *៤៨៦,៤៥ លានដុល្លារអាមេរិក* ក្នុងនោះជាមួយៈ

- ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី (មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម និងធនាគារអភិវឌ្ឍន៍អាស៊ី) មានកិច្ចព្រមព្រៀងចំនួន ១១ ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *១៨៧,៨៤ លានដុល្លារអាមេរិក* និង
- រដ្ឋាភិបាលបរទេស (សាធារណរដ្ឋប្រជាមានិតចិន និងទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍បារាំង) មានកិច្ចព្រមព្រៀងចំនួន ០៥ ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *២៩៨,៦១ លានដុល្លារអាមេរិក*។

ដោយគិតបញ្ចូលទាំងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅក្នុង**ឆមាសទី១ និងឆមាសទី២** សម្រាប់ឆ្នាំ ២០១៦ នេះ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានសរុបចំនួន **២៣** ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *៨០២,០៥ លានដុល្លារអាមេរិក* (គិតតាមអត្រាប្តូរប្រាក់ផ្លូវការដែលចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦) ក្នុងនោះ ជាមួយរដ្ឋាភិបាលបរទេសនានាមានកិច្ចព្រមព្រៀងចំនួន ០៨ ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *៤៨៧,២០ លានដុល្លារអាមេរិក* និងជាមួយស្ថាប័នហិរញ្ញវត្ថុ អន្តរជាតិពហុភាគី មានកិច្ចព្រមព្រៀងចំនួន **១៥** ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *៣១៤,៨៤ លានដុល្លារអាមេរិក*។

ដូច្នេះ បើគិតតាមអត្រាប្តូរប្រាក់ផ្លូវការដែលចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ គឺៈ ១ ដុល្លារអាមេរិក = ០.៧៤២៥០៥ អេសដេអ៊ែរ (SDR), ក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានចុះហត្ថលេខា ខ្ចីឥណទានសម្បទានពីរដ្ឋាភិបាលបរទេសនានា និង ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី មានទឹកប្រាក់សរុបចំនួន ប្រមាណ *៥៩៥,៥២ លាន SDR* លើទំហំទឹកប្រាក់ចំនួន *៧០០ លាន SDR* ដែលបានអនុញ្ញាតដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។ ដោយឡែក សម្រាប់ឆមាសទីពីរ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានចុះហត្ថលេខាខ្ចីឥណទានសម្បទានពីរដ្ឋាភិបាលបរទេសនានា និងពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគីមានទឹកប្រាក់ សរុបចំនួនប្រមាណ *៣៦១,២០ លាន SDR*។

ទន្ទឹមនឹងការកៀរគរឥណទានសម្បទាន ទោះបីជាកម្រិតនៃហិរញ្ញប្បទានឥតសំណងបច្ចុប្បន្នកាន់តែមានការថយចុះក៏ដោយ ក្រោមការដឹកនាំផ្ទាល់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន និងបន្តខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការកៀរគរហិរញ្ញប្បទានឥតសំណងបន្ថែមទៀត ដើម្បីធ្វើជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ហិរញ្ញប្បទាន ឬសហហិរញ្ញប្បទាន ឬហិរញ្ញប្បទានផ្ទាល់ទាំងស្រុងលើគម្រោងវិនិយោគមួយចំនួនសំដៅបង្កើនល្បឿននៃការអភិវឌ្ឍ ការកាត់បន្ថយភាពក្រីក្រ និងរក្សាបន្ទុកបំណុលឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

ការចុះហត្ថលេខាទទួលឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង សម្រាប់ហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍នៅក្នុងឆមាសទី២ ឆ្នាំ២០១៦ រួមមានដូចខាងក្រោមៈ

## ក- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង

នៅក្នុងឆមាសទីពីរ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងចំនួន ០៨ ដែលមានទឹកប្រាក់សរុបទាំងអស់ចំនួន *២១២,១០ លានដុល្លារអាមេរិក* ដូចខាងក្រោមៈ

### ក.១ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

-កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី២ (ហិរញ្ញប្បទានបន្ថែម) មានទឹកប្រាក់សរុបចំនួន *១,៥០ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ ADB នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦។

### ក.២ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD)

-កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង (ហិរញ្ញប្បទានបន្ថែម) ស្តីពីគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច ដែលមានទឹកប្រាក់សរុបចំនួន *៤,៦០ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ IFAD នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦។

### ក.៣ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស មានទឹកប្រាក់សរុបចំនួន ៣៣២ លានយ៉េនជប៉ុន ត្រូវជាប្រមាណ *២,៨៧ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ JICA នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦។

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងពង្រីកបណ្តាញចែកចាយអគ្គិសនី ស្ថិតក្នុងច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង មានទឹកប្រាក់សរុបចំនួន ៨៩៣ លានយ៉េនជប៉ុន ត្រូវជាប្រមាណ *៧,៩១ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ JICA នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦។

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពដឹកជញ្ជូននៃរថយន្តក្រុង ក្នុងរាជធានីភ្នំពេញ មានទឹកប្រាក់សរុបចំនួន ១ ៣៦៩ លានយ៉េនជប៉ុន ត្រូវជាប្រមាណ *១២,០៥ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹង JICA នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

### ក.៤ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងមូលនិធិសម្រាប់ការសិក្សា និងពង្រឹងសមត្ថភាព មានទឹកប្រាក់សរុបចំនួន ០,៥០ លានអឺរ៉ូ ត្រូវជាប្រមាណ *០,៥៣ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ AFD នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦។

### ក.៥ ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW)

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពីគម្រោងកម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ជំហានទី៥ មានទឹកប្រាក់សរុបចំនួន ៩ លានអឺរ៉ូ ត្រូវជាប្រមាណ *៩,៥៦ លានដុល្លារអាមេរិក* ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយ KfW នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

ក.៦ សាធារណរដ្ឋប្រជាមានិតចិន

- កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ស្តីពី៖ ១) គម្រោងសាងសង់អគារពេទ្យមិត្តភាព កម្ពុជា-ចិន នៅមន្ទីរពេទ្យព្រះកុសមៈ, ២) គម្រោងសាងសង់មន្ទីរពេទ្យខេត្តត្បូងឃ្មុំ, និង ៣) គម្រោងសាងសង់វិទ្យាស្ថានធនធានទឹក។ គម្រោងទាំង ០៣ ខាងលើមានទឹកប្រាក់សរុបចំនួន **១ ២០០ លានយ័នចិន** ត្រូវជាប្រមាណ ***១៧៣,៣០ លានដុល្លារអាមេរិក*** (តាមអត្រាប្តូរប្រាក់របស់ធនាគារចិននៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ គឺ៖ ១ ដុល្លារអាមេរិក= ៦,៧២៩២ យ័នចិន) ត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។

ជាមួយគ្នានេះ ក្នុងខែតុលា ឆ្នាំ២០១៦ មានការចុះហត្ថលេខាផងដែរលើពិធីសារស្តីពីការលុបបំណុលរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលមានទឹកប្រាក់សរុបចំនួន ៦២៧,៦២ លានយ័នចិន ត្រូវជាប្រមាណ *៩០,៦៤ លានដុល្លារអាមេរិក* (តាមអត្រាប្តូរប្រាក់របស់ធនាគារចិននៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ គឺ៖ ១ ដុល្លារអាមេរិក = ៦,៧២៩២ យ័នចិន)។ បំណុលទាំងនេះត្រូវបានលុបចេញពីកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ចំនួន ០៦ ដូចខាងក្រោម៖

១) កិច្ចព្រមព្រៀងចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលមានទឹកប្រាក់ចំនួន ៥០ លានយ័នចិន។
២) កិច្ចព្រមព្រៀងចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ ដែលមានទឹកប្រាក់ចំនួន ៨០ លានយ័នចិន។
៣) កិច្ចព្រមព្រៀងចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលមានទឹកប្រាក់ចំនួន ៥០ លានយ័នចិន។
៤) កិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ដែលមានទឹកប្រាក់ចំនួន ២០០ លានយ័នចិន។
៥) កិច្ចព្រមព្រៀងចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៤ ដែលមានទឹកប្រាក់ចំនួន ២០០ លានយ័នចិន។
៦) កិច្ចព្រមព្រៀងចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ ដែលមានទឹកប្រាក់ចំនួន ៥០ លានយ័នចិន។

## ខ- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទាន

នៅក្នុងឆមាសទីពីរ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ១៦ គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណ ៣៦១,២០ លាន SDR ត្រូវជាប្រមាណ *៤៨៦,៤៥ លានដុល្លារអាមេរិក* ជាមួយរដ្ឋាភិបាលបរទេសនានា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី។

ខ.១ កិច្ចព្រមព្រៀងឥណទានសម្បទាន ជាមួយរដ្ឋាភិបាលបរទេស

ខ.១.១ សាធារណរដ្ឋប្រជាមានិតចិន

ក្នុងឆមាសទីពីរ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០៤ គម្រោង ជាមួយសាធារណរដ្ឋប្រជាមានិតចិន ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ *២៦៦,៧៦ លានដុល្លារអាមេរិក* ដែលក្នុងនោះមាន៖

១- កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសជាឥណទានឥតការប្រាក់ សម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូ ជំហានទី ២

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានជាមួយរដ្ឋាភិបាលចិន ដែលមានទឹកប្រាក់សរុបចំនួន ៦១១,៦៩ លានយ័នចិន ត្រូវជាប្រមាណ *៨៨,៣៤ លានដុល្លារអាមេរិក* ក្នុងនោះមាន៖ ក) កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិនចំនួន ៣៨២,៣១ លានយ័នចិន ត្រូវជាប្រមាណ *៥៥,២១ លានដុល្លារអាមេរិក* និង ខ) កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសជាឥណទានឥតការប្រាក់ចំនួន ២២៩,៣៨ លានយ័នចិន ត្រូវជា ប្រមាណ *៣៣,១៣ លានដុល្លារអាមេរិក* សម្រាប់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃកូ ដំណាក់ទី ២។

គម្រោងនេះ មានទីតាំងគ្របដណ្តប់លើស្រុកកំពង់ត្របែក និងស្រុកព្រៃវែង នៃខេត្តព្រៃវែង និងស្រុក រំដួល, ស្រុកស្វាយរៀង, ស្រុកស្វាយទាប, ស្រុកស្វាយជ្រំ, និងស្រុកកំពង់រោទ៍ នៃខេត្តស្វាយរៀង ដែលក្នុងនោះ មានការងារសំខាន់ៗដូចជា៖ ១) ជីកព្រែកចំនួន ០២ ខ្សែ មានប្រវែងសរុប ១៤,៦ គីឡូម៉ែត្រ, ២) ជីកប្រឡាយមេ ចំនួន ០៤ ខ្សែ មានប្រវែងសរុប ៥៩,៥ គីឡូម៉ែត្រ, ៣) សាងសង់ទំនប់សណ្តរប្រវែង ៤១,៥ គីឡូម៉ែត្រ, ៤) សំណង់បង្ហៀរទឹក ០១ កន្លែង, ៥) សំណង់ស្ទាក់ទឹក ០៦ កន្លែង និងសំណង់សម្រួលចន្លោទឹក ០៨ កន្លែង, និង ៦) ស្ថានីយ៍បូមទឹក ០៤ កន្លែង និងសំណង់លូទឹក ៣២ កន្លែង។ គម្រោងនេះ គ្រោងអនុវត្តរយៈពេល ០៤ ឆ្នាំ (២០១៦ - ២០១៩) ដោយមានក្រសួងធនធានទឹក និងឧតុនិយម ជាភ្នាក់ងារប្រតិបត្តិគម្រោង។

**២- កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ជាឥណទានឥតការប្រាក់ សម្រាប់គម្រោងសាងសង់ផ្លូវជាតិលេខ ៥១**

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានមានទឹកប្រាក់សរុបចំនួន ២៥៩,០៣ លានយ័នចិន ត្រូវជាប្រមាណ *៣៧,៤១ លានដុល្លារអាមេរិក* ក្នុងនោះមាន៖ ក) កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិនចំនួន ១៦១,៨៩ លានយ័នចិន ត្រូវជាប្រមាណ *២៣,៣៨ លានដុល្លារអាមេរិក* និង ខ) កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសជាឥណទានឥតការប្រាក់ចំនួន ៩៧,១៤ លានយ័នចិន ត្រូវជាប្រមាណ *១៤,០៣ លានដុល្លារអាមេរិក* សម្រាប់ហិរញ្ញប្បទានលើគម្រោងសាងសង់ផ្លូវជាតិលេខ ៥១។

គម្រោងនេះ មានទិសដៅសាងសង់ផ្លូវជាតិលេខ ៥១ ពីថ្នល់ទទឹង (ផ្លូវជាតិលេខ ៤) ដល់ឧត្តុង្គ (ផ្លូវជាតិលេខ ៥) មានប្រវែងសរុប ៣៧,៩៥ គីឡូម៉ែត្រ តាមស្តង់ដារចិន Class II សម្រាប់ល្បឿន ៨០ គីឡូម៉ែត្រ/ម៉ោង ដោយមានទទឹងតួថ្នល់ប្រវែង ១២ ម៉ែត្រ, ទទឹងទ្រូងផ្លូវក្រាលកៅស៊ូ AC ១១ ម៉ែត្រ ក្នុងនោះមានគន្លងផ្លូវរថយន្តទទឹង ៣,៧៥ ម៉ែត្រ ចំនួន ០២ គន្លង និងគន្លងផ្លូវទោចក្រយានយន្តទទឹង ១,៧៥ ម៉ែត្រ ចំនួន ០២ គន្លងផងដែរ។

គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ០៣ ឆ្នាំ (២០១៦ - ២០១៨) ដោយមានក្រសួងសាធារណការ និងដឹកជញ្ជូន ជាភ្នាក់ងារប្រតិបត្តិគម្រោង។

**៣- កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី ២ ក្នុងរាជធានីភ្នំពេញ**

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានមានទឹកប្រាក់សរុបចំនួន ៣៨៨ លានយ័នចិន ត្រូវជាប្រមាណ *៥៦,០៣ លានដុល្លារអាមេរិក* សម្រាប់ហិរញ្ញប្បទានលើគម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី ២ ស្ថិតក្នុងរាជធានីភ្នំពេញ។

គម្រោងនេះ មានទិសដៅសាងសង់ផ្លូវក្រវាត់ក្រុងទី ២ ដោយចាប់ពីមហាវិថីសហព័ន្ធរុស្ស៊ីឆ្លងកាត់ផ្លូវ North Bridge, ផ្លូវចោមចៅ, តំបន់សួនឧស្សាហកម្មវឌ្ឍនៈ រួចភ្ជាប់ទៅផ្លូវជាតិលេខ ២ ត្រង់ចំណុចប្រសព្វផ្លូវ

ទៅស្ពានមិត្តភាពកម្ពុជា-ចិន នៅទីក្រុងតាខ្មៅ មានប្រវែងសរុប ១៦,៥៦៣ គីឡូម៉ែត្រ និងទទឹងប្រវែង ២៣ ម៉ែត្រ ក្រាលបេតុងស៊ីម៉ង់ត៍កម្រាស់ ២០ សង់ទីម៉ែត្រ និងទទឹងថ្លុងផ្លូវប្រវែង ១៨,៧០ ម៉ែត្រ ដោយមានគន្លងផ្លូវរថយន្ត ០៤ គន្លង ទទឹង ៣,៥០ ម៉ែត្រ/គន្លង, គន្លងទោចក្រយានយន្តមាន ០២ គន្លង ទទឹង ២,៣៥ ម៉ែត្រ/ គន្លង, ស្ពានរំលងមួយកន្លែងប្រវែង ៦១០ ម៉ែត្រ ទទឹង ១៦,៥០ ម៉ែត្រ, អគារ-ឧបករណ៍ថ្លឹងរថយន្ត ០២ កន្លែង និងបំពាក់ភ្លើងស្តុប ០៦ កន្លែង។ គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ០៣ ឆ្នាំ (២០១៦ - ២០១៨) ដោយមានក្រសួងសាធារណការ និងដឹកជញ្ជូន ជាភ្នាក់ងារអនុវត្តគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទានជាប្រាក់យ័នចិន សម្រាប់គម្រោងទាំង ០៣ ខាងលើ មានដូចតទៅៈ

-រយៈពេលខ្ចី៖ ២០ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៧ ឆ្នាំ
-រយៈពេលសង៖ ១៣ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០៣៥
-ការប្រាក់៖ ២% ក្នុងមួយឆ្នាំ នៃទឹកប្រាក់ដែលបានដកយកមកប្រើ
-កម្រៃគ្រប់គ្រង៖ ០,២%
-កម្រៃសន្យា៖ ០,២%

ចំពោះលក្ខខណ្ឌនៃឥណទានឥតការប្រាក់ជាប្រាក់យ័នចិនសម្រាប់គម្រោងទាំង ០២ ខាងលើ រាជរដ្ឋាភិបាលកម្ពុជា ត្រូវសងវិញជាប្រាក់រំលស់មួយឆ្នាំម្តង ក្នុងអំឡុងពេល ១០ ឆ្នាំ (ឆ្នាំ២០២៦ - ២០៣៦) ជាប្រាក់យ័នចិន ឬ រូបិយវត្ថុអាចប្តូរបានសេរី ឬ ជាមួយនឹងទំនិញនាំចេញរបស់កម្ពុជា តាមការព្រមព្រៀងរវាងរដ្ឋាភិបាលទាំងពីរ។ រាល់ទឹកប្រាក់សងប្រចាំឆ្នាំ ត្រូវមានទំហំស្មើនឹងមួយភាគដប់នៃទឹកប្រាក់ឥណទាន។

### ៤- កិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីជនបទដំណាក់កាលទី ៥ និងទី ៦

នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់ដុល្លារអាមេរិក ដែលមានទឹកប្រាក់ចំនួន *៨៤,៩៨ លានដុល្លារអាមេរិក* សម្រាប់ហិរញ្ញប្បទានលើគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីជនបទ ដំណាក់កាលទី ៥ និងទី ៦។

លក្ខខណ្ឌនៃឥណទាន មានដូចតទៅៈ

-រយៈពេលខ្ចី៖ ២០ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៧ ឆ្នាំ
-រយៈពេលសង៖ ១៣ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០៣៥
-ការប្រាក់៖ ២% ក្នុងមួយឆ្នាំនៃទឹកប្រាក់ដែលបានដកយកមកប្រើ
-កម្រៃគ្រប់គ្រង៖ ០,២%
-កម្រៃសន្យា៖ ០,២%

គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីជនបទ ដំណាក់កាលទី ៥ មានទិសដៅស្ថាបនាខ្សែបណ្តាញចែកចាយអគ្គិសនីតង់ស្យុង ៣៥ គីឡូវ៉ុល ប្រវែង ៧៥០ គីឡូម៉ែត្រ, ខ្សែបណ្តាញចែកចាយអគ្គិសនី ២២ គីឡូវ៉ុល ប្រវែង ៦៣៥ គីឡូម៉ែត្រ, និងខ្សែបញ្ជូនអគ្គិសនីតង់ស្យុង ១១៥ គីឡូវ៉ុល ប្រវែង ១០ គីឡូម៉ែត្រ ក្នុងខេត្តកំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, មណ្ឌលគីរី, និងខេត្តរតនគីរី និងសំណង់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធមួយចំនួនទៀត។ សម្រាប់ដំណាក់កាលទី ៦ គម្រោងនឹងស្ថាបនាខ្សែបណ្តាញចែកចាយអគ្គិសនីតង់ស្យុង ៣៥ គីឡូវ៉ុល ប្រវែង ៤០០ គីឡូម៉ែត្រ, ខ្សែបណ្តាញចែកចាយអគ្គិសនី ២២ គីឡូវ៉ុល ប្រវែង ៨០០ គីឡូម៉ែត្រ, និងខ្សែបញ្ជូនអគ្គិសនីតង់ស្យុង

១១៥ គីឡូវ៉ុល ប្រវែង ១២ គីឡូម៉ែត្រ ក្នុងខេត្តសៀមរាប, ឧត្តរមានជ័យ, ពោធិ៍សាត់, ព្រះវិហារ, និងខេត្តព្រៃវែង និងសំណង់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធមួយចំនួនទៀត។

គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ០៣ ឆ្នាំ(២០១៧ - ២០១៩) ដោយមានអគ្គិសនីកម្ពុជា ជាភ្នាក់ងារប្រតិបត្តិគម្រោង។

**ខ.១.២ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)**

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានជាប្រាក់អឺរ៉ូ ជាមួយនឹង AFD ដែលមានទឹកប្រាក់ចំនួន ៣០ លានអឺរ៉ូ ត្រូវជាប្រមាណ ***៣១,៨៥ លានដុល្លារអាមេរិក*** សម្រាប់ហិរញ្ញប្បទានលើគម្រោងពង្រីកសមត្ថភាពរោងចក្រផលិតទឹកស្អាតចំការមន និងប្រព័ន្ធចែកចាយទឹក។

គម្រោងនេះ មានសមាសភាគសំខាន់ៗចំនួន ០៣ គឺ៖ ១) សមាសភាគទី១: ការងារសាងសង់រោងចក្រផលិតទឹកស្អាតចំការមន ដែលមានសមត្ថភាពបង្កើនផលិតទឹកស្អាតឱ្យបានដល់ ៥៣ ០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ ខណៈពេលបច្ចុប្បន្នអាចផលិតបានតែ ១៤ ០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ, ២) សមាសភាគទី២: ការផ្លាស់ប្តូរបំពង់មេនាំទឹក, បំពង់ចែកចាយទឹក, និងការកសាងទីស្នាក់ការកណ្តាលស្ថានីយ៍បូមទឹក, និង ៣) សមាសភាគទី៣: ការកសាងសមត្ថភាពមន្ត្រីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។ គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ០៣ ឆ្នាំ (២០១៧ - ២០១៩) ដោយមានរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

-រយៈពេលខ្ចី៖ ២០ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៧ ឆ្នាំ

-រយៈពេលសង៖ ១៣ ឆ្នាំ

-អត្រាការប្រាក់៖ ០,២៥% ទៅ ២% ក្នុងមួយឆ្នាំ

**ខ.២ កិច្ចព្រមព្រៀងឥណទានសម្បទាន ជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី**

**ខ.២.១ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD)**

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា និង IFAD បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥណទានសម្បទាន(ហិរញ្ញប្បទានបន្ថែម) ស្តីពីគម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច មានទឹកប្រាក់សរុបចំនួន ២,១ លាន SDR ត្រូវជាប្រមាណ ***២,៨៣ លានដុល្លារអាមេរិក***។

គោលបំណងចំបងនៃគម្រោងនេះ គឺការកែលម្អជីវភាពរបស់កសិករក្រីក្រតាមមូលដ្ឋាននានាក្នុងឃុំចំនួនប្រមាណ ២៤៦ ឃុំ នៃស្រុកចំនួន ៣៦ ក្នុងខេត្តគោលដៅចំនួន ០៥ គឺ៖ ខេត្តព្រៃវែង, ស្វាយរៀង, កណ្តាល, តាកែវ, និងខេត្តកំពត និងមានការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញផលិតកម្មស្រូវ និងការនាំអង្ករចេញក្រៅប្រទេស ។ គម្រោងនេះ គ្រោងអនុវត្តរយៈពេល ០៦ ឆ្នាំ (២០១២ - ២០១៨) ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

-រយៈពេលខ្ចី៖ ៤០ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ១០ ឆ្នាំ

-រយៈពេលសង៖ ៣០ ឆ្នាំ

-កម្រៃសេវា៖ ០,៧៥% ក្នុងមួយឆ្នាំ

**ខ.២.២ ធនាគារអភិវឌ្ឍន៍អាស៊ី**

ក្នុងឆមាសទីពីរ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ១០ គម្រោង ជាមួយ ADB ដែលមានទឹកប្រាក់សរុបប្រមាណ *១៨៥,០១ លានដុល្លារអាមេរិក* សម្រាប់គម្រោង និងកម្មវិធី ដែលក្នុងនោះមាន៖

**១- កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ កម្មវិធី ដែលមានទឹកប្រាក់ចំនួន ១០,៧៥ លាន SDR ត្រូវជាប្រមាណ *១៤,៤៨ លានដុល្លារអាមេរិក*។ កម្មវិធីនេះ មានគោលបំណងកែលម្អប្រសិទ្ធភាពប្រព័ន្ធអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ តាមរយៈ៖ ១) ការរៀបចំដាក់ឱ្យអនុវត្តនូវកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងសិស្សពូកែ, ២) ការកែលម្អគោលនយោបាយជ្រើសរើស និងពង្រាយគ្រូបង្រៀន, ៣) ការពង្រឹងកម្មវិធីអប់រំដោយការរៀបចំឱ្យមានគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម, និងគណិតវិទ្យា, ៤) ការរៀបចំបញ្ញត្តិនៃការធានាគុណភាពអប់រំ និងកែសម្រួលសេចក្តីណែនាំទាក់ទងនឹងសាលាមធ្យមសិក្សាជនបទ, ៥) ការកែលម្អឡើងវិញនូវកម្មវិធីសិក្សា និងប្រព័ន្ធវាយតម្លៃអប់រំចំណេះទូទៅ, ៦) ការពង្រឹងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈគ្រូបង្រៀន, ៧) ការកែសម្រួលមុខងាររបស់អង្គភាពពាក់ព័ន្ធក្នុងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន, និង ៨) ការរៀបចំធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤ - ២០១៨។

កម្មវិធីនេះ គ្រោងអនុវត្តក្នុងរយៈពេល ២ ឆ្នាំ (ឆ្នាំ២០១៦ - ២០១៧) ដោយមានក្រសួងអប់រំ យុវជន និងកីឡា ជាភ្នាក់ងារប្រតិបត្តិកម្មវិធី។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

-រយៈពេលខ្ចី៖ ២៤ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
-រយៈពេលសង៖ ១៦ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤០
-អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង១,៥% ក្នុងមួយឆ្នាំសម្រាប់រយៈពេលបន្ទាប់

**២- គម្រោងអភិវឌ្ឍន៍វិស័យអប់រំកម្រិតទុតិយភូមិ**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ១ គម្រោង ដែលមានទឹកប្រាក់ចំនួន ២១,៥១ លាន SDR ត្រូវជាប្រមាណ *២៨,៩៦ លានដុល្លារអាមេរិក*។ គម្រោងនេះ មានគោលបំណងចម្បងគឺ៖ ១) ការបង្កើនលទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ, ២) ការកែលម្អគុណភាពអប់រំ និងភាពឆ្លើយតបនៅកម្រិតមធ្យមសិក្សាទុតិយភូមិ, និង ៣) ការពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ, ការគ្រប់គ្រង និងផ្តល់សេវាអប់រំ។

គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ៦ ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២២) ដោយមានក្រសួងអប់រំ យុវជន និងកីឡា ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

-រយៈពេលខ្ចី៖ ៣២ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
-រយៈពេលសង៖ ២៤ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤៨
-អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង ១,៥% ក្នុងមួយឆ្នាំសម្រាប់រយៈពេលបន្ទាប់

**៣- កម្មវិធីកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុ (អនុកម្មវិធីទី២)**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ កម្មវិធី ដែលមានទឹកប្រាក់សរុបចំនួន ១០,៧៣ លាន SDR ត្រូវជាប្រមាណ *១៤,៤៥ លានដុល្លារអាមេរិក*។ កម្មវិធីនេះ មានគោលបំណងគាំទ្រដល់៖ ១) ការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ, ២) ការរៀបចំស្ថាប័ន ដែលមានតួនាទីជាអ្នកសម្របសម្រួល និងរៀបចំគោលនយោបាយអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ, ៣) ការកំណត់មុខងារទទួលខុសត្រូវលើសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ, ៤) ការរៀបចំប្រព័ន្ធវិមជ្ឈការសារពើពន្ធ ដោយផ្តោតលើការពង្រីកមូលដ្ឋានប្រមូលពន្ធ, ៥) ការរៀបចំ និងបង្កើនប្រសិទ្ធិភាពប្រព័ន្ធផ្ទេរថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គម្រោងអភិវឌ្ឍន៍, ៦) ការរៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់ប្រព័ន្ធវិមជ្ឈការគ្រប់គ្រងហិរញ្ញវត្ថុ, និង ៧) ការរៀបចំប្រព័ន្ធពិគ្រោះយោបល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

កម្មវិធីនេះ គ្រោងអនុវត្តរយៈពេល ០៤ ឆ្នាំ (២០១៣ - ២០១៧) ដោយមានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាភ្នាក់ងារប្រតិបត្តិកម្មវិធី។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

- រយៈពេលខ្ចី៖ ២៤ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
- រយៈពេលសង៖១៦ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤០
- អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង ១,៥ % ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

**៤-គម្រោងកំណែទម្រង់វិមជ្ឈការសេវាសាធារណៈ និងហិរញ្ញវត្ថុ (អនុកម្មវិធីទី២)**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ គម្រោង ដែលមានទឹកប្រាក់ចំនួន ១៤,៣១ លាន SDR ត្រូវជាប្រមាណ *១៩,២៧ លានដុល្លារអាមេរិក*។ គោលបំណងនៃគម្រោងគឺ៖ ១) ការគាំទ្រលើផ្នែកវិនិយោគរបស់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសផ្តោតសំខាន់លើអនុគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានស្នើឡើង ដោយរដ្ឋបាលថ្នាក់មូលដ្ឋាន និង ២) ការគាំទ្រលើផ្នែកប្រតិបត្តិការរបស់លេខាធិការដ្ឋានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

គម្រោងនេះ គ្រោងអនុវត្តរយៈពេល ០៦ ឆ្នាំ (២០១៦ - ២០២២) ដែលមានលេខាធិការដ្ឋានមូលនិធិវិនិយោគ រដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅៈ

- រយៈពេលខ្ចី៖ ៣២ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
- រយៈពេលសង៖ ២៤ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤៨
- អត្រាការប្រាក់៖១% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលអនុគ្រោះ និង ១,៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

**៥- កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អនុកម្មវិធីទី១)**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ កម្មវិធី ដែលមានទឹកប្រាក់ចំនួន ១៨,៩៤ លាន SDR ត្រូវជាប្រមាណ *២៥,៥១ លានដុល្លារអាមេរិក*។ កម្មវិធីនេះ មានគោលបំណងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ៖ ១) ការពង្រឹងក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) ការពង្រឹងសមត្ថភាពក្រសួង ស្ថាប័នអនុវត្តកំណែទម្រង់ការគ្រប់គ្រង និងចំណាយហិរញ្ញវត្ថុសាធារណៈ, និង ៣) ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងតួនាទីរបស់សវនកម្មផ្ទៃក្រៅ ដោយផ្តោតលើការរៀបចំក្របខ័ណ្ឌបទដ្ឋាន

គតិយុត្ត និងសមត្ថភាពសម្រាប់ការពង្រឹងសវនកម្មផ្ទៃក្រៅ។

កម្មវិធីនេះ គ្រោងអនុវត្តរយៈពេល ០៤ ឆ្នាំ (២០១៤ - ២០១៧) ដោយមានលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាភ្នាក់ងារប្រតិបត្តិកម្មវិធី។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

-រយៈពេលខ្ចី៖ ២៤ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ

-រយៈពេលសង៖ ១៦ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤០

-អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង ១,៥% ក្នុង មួយឆ្នាំសម្រាប់រយៈពេលបន្ទាប់

**៦-គម្រោងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ គម្រោង ដែលមានទឹកប្រាក់ចំនួន ២,៥០ លាន SDR ត្រូវជាប្រមាណ ***៣,៣៧ លានដុល្លារអាមេរិក***។ គម្រោងនេះ មានគោលគោលបំណងចម្បង គឺ៖ ១) ការជួយពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំ ក្នុងការងារសម្របសម្រួល និងគ្រប់គ្រងការអនុវត្តកម្មវិធី, ២) ការពង្រឹងសមត្ថភាពក្រសួង-ស្ថាប័នមួយចំនួន ដូចជា៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹក និងឧតុនិយម លើការគ្រប់គ្រងថវិកា, គណនេយ្យ, ហិរញ្ញវត្ថុ, និងសវនកម្មផ្ទៃក្នុង, និង ៣) ការពង្រឹងសមត្ថភាពក្នុងការធ្វើសវនកម្មផ្ទៃក្រៅរបស់អជ្ញាធរសវនកម្មជាតិ តាមរយៈការកែលម្អការត្រួតពិនិត្យសវនកម្ម ។

គម្រោងនេះ គ្រោងអនុវត្តរយៈពេល ០៤ ឆ្នាំ (២០១៧ - ២០២០) ដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាភ្នាក់ងារប្រតិបត្តិគម្រោង និងមានការចូលរួមអនុវត្ត ពីអគ្គនាយកដ្ឋានពាក់ព័ន្ធមួយចំនួនរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អាជ្ញាធរសវនកម្មជាតិ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងអភិវឌ្ឍន៍ជនបទ, និងក្រសួងធនធានទឹក និងឧតុនិយម។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

- រយៈពេលខ្ចី៖ ៣២ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
- រយៈពេលសង៖ ២៤ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤៨
- អត្រាការប្រាក់៖១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង ១,៥ % ក្នុងមួយឆ្នាំសម្រាប់រយៈពេលបន្ទាប់

**៧- គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដំណាក់កាលទី២ (ហិរញ្ញប្បទានបន្ថែម)**

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ គម្រោង ដែលមានទឹកប្រាក់ចំនួន ១០,៨៤ លាន SDR ត្រូវជាប្រមាណ ***១៤,៥៩ លានដុល្លារអាមេរិក***។ គម្រោងនេះ មានគោលបំណងចម្បង គឺការបន្តអនុវត្តពីគម្រោងដំណាក់កាលទី២ មុន ដោយធ្វើការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅក្នុងខេត្តចំនួន ០៦ (ស្រុកចំនួន ១៣ និងឃុំចំនួន ២៨) ដែលរួមមាន៖ ខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, សៀមរាប, កំពង់ធំ, និងខេត្តបន្ទាយមានជ័យ។

គម្រោងនេះ គ្រោងអនុវត្តរយៈពេល ០៤ ឆ្នាំ (២០១៦ - ២០២០) ដោយមានក្រសួងអភិវឌ្ឍន៍ជនបទ ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចតទៅ៖

- រយៈពេលខ្ចី៖ ៣២ ឆ្នាំ ដោយមានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
- រយៈពេលសង៖២៤ ឆ្នាំ ចាប់ផ្តើមពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០៤៨
- អត្រាការប្រាក់៖១% ក្នុងមួយឆ្នាំសម្រាប់រយៈពេលអនុគ្រោះ និង ១,៥ % ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

**៨- គម្រោងកែលម្អផ្លូវខេត្ត (ហិរញ្ញប្បទានបន្ថែម)**

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ គម្រោង ដែលមានទឹកប្រាក់ចំនួន ៤,២៧ លាន SDR ត្រូវជាប្រមាណ ***៥,៧៥ លានដុល្លារអាមេរិក***។ ហិរញ្ញប្បទានបន្ថែមនេះ នឹងត្រូវប្រើប្រាស់សម្រាប់សាងសង់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម (ព្រៃវល្លិ៍ ខេត្តស្វាយរៀង)។

គម្រោងនេះ គ្រោងអនុវត្តក្នុងរយៈពេល ០២ ឆ្នាំ (២០១៧ - ២០១៨) ដែលមានក្រសួងសាធារណការ និងដឹកជញ្ជូន ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចខាងក្រោម៖
- រយៈពេលខ្ចី៖ ៣២ ឆ្នាំ ក្នុងនោះ មានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
- រយៈពេលសង៖ ២៤ ឆ្នាំ ក្នុងនោះ ចាប់ផ្តើមពីឆ្នាំ២០២៤ ដល់ឆ្នាំ២០៤៨
- អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលអនុគ្រោះ និង១,៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

***៩-កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន(អនុកម្មវិធីទី១)***

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០១ កម្មវិធី ដែលមានទឹកប្រាក់ចំនួន ២៨,៥៣ លាន SDR ត្រូវជាប្រមាណ ***៣៨,៤២ លានដុល្លារអាមេរិក***។ គោលបំណងចម្បង នៃកម្មវិធីអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន (អនុកម្មវិធីទី១) គឺសម្រាប់បន្តអនុវត្តកម្មវិធីកំណែទម្រង់សំខាន់ៗជាអាទិភាពក្នុងវិស័យហិរញ្ញវត្ថុ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១ - ២០២០ ឱ្យកាន់តែរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារ ដែលបម្រើឱ្យការកៀរគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព សំដៅរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រមួយកម្រិតថែមទៀត ។

កម្មវិធីនេះគ្របដណ្តប់ជាចម្បងទៅលើ៖ ១) ការពង្រីកសេវាកម្មហិរញ្ញវត្ថុឱ្យបានទូលំទូលាយ, ២) ការបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋលើសេវាហិរញ្ញវត្ថុ និងការធ្វើឱ្យប្រសើរឡើងនូវស្ថិរភាពហិរញ្ញវត្ថុ, និង ៣) ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុផ្សេងៗ ដែលគាំទ្រដល់វិស័យឯកជននិងហិរញ្ញវត្ថុ។

កម្មវិធីនេះ គ្រោងអនុវត្តក្នុងរយៈពេល ០៣ ឆ្នាំ (២០១៤ - ២០១៧) ដោយមានធនាគារជាតិនៃកម្ពុជា ជា ភ្នាក់ងារប្រតិបត្តិកម្មវិធី និងចូលរួមអនុវត្តដោយក្រសួងសេដ្ឋកិច្ច និ ងហិរញ្ញវត្ថុ, ក្រ សួងពាណិជ្ជកម្ម, និងគណៈកម្មការមូលបត្រកម្ពុជា ។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចខាងក្រោម៖
-រយៈពេលខ្ចី៖ ២៤ ឆ្នាំ ក្នុងនោះ មានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
-រយៈពេលសង៖ ១៦ ឆ្នាំ ក្នុងនោះ ចាប់ផ្តើមពីឆ្នាំ២០២៥ ដល់ឆ្នាំ២០៤០
-អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលអនុគ្រោះ និង១,៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

**១០- គម្រោងទប់ស្កាត់ និងបង្ការជម្ងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ**

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ រាជរដ្ឋាភិបាល និង ADB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ០២ គម្រោង ដែលមានទឹកប្រាក់ចំនួន ១៥,០១ លាន SDR ត្រូវជាប្រមាណ ***២០,២២ លានដុល្លារអាមេរិក***។ គោលបំណងចម្បងនៃគម្រោង គឺទប់ស្កាត់ និងបង្ការជម្ងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ តាមរយៈការផ្តល់ការគាំទ្រដល់៖ ១) ការធ្វើឲ្យប្រសើរនូវកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការត្រួតពិនិត្យជម្ងឺឆ្លងតាមតំបន់ព្រំដែន, ២) ការពង្រឹងប្រព័ន្ធជាតិតាមដាន និងឆ្លើយតបនឹងជម្ងឺ, និង ៣) ការធ្វើឲ្យប្រសើរឡើងនូវសេវាក្នុងមន្ទីរពិសោធន៍ និងមន្ទីរពេទ្យ ក្នុងខេត្តគោលដៅចំនួន ១២ គឺ៖ ខេត្តកំពត, តាកែវ, កណ្តាល, ព្រៃវែង, ស្វាយរៀង, កំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, ស្ទឹងត្រែង, មណ្ឌលគិរី, រតនគិរី, និងខេត្តព្រះវិហារ ។

គម្រោងនេះ គ្រោងអនុវត្តរយៈពេលអនុវត្ត ០៦ ឆ្នាំ (២០១៧ - ២០២២) ដោយមានក្រសួងសុខាភិបាល ជាភ្នាក់ងារប្រតិបត្តិគម្រោង។

លក្ខខណ្ឌនៃឥណទានសម្បទាន មានដូចខាងក្រោម៖

-រយៈពេលខ្ចី៖ ៣២ ឆ្នាំ ក្នុងនោះ មានរយៈពេលអនុគ្រោះ ០៨ ឆ្នាំ
-រយៈពេលសង៖ ២៤ ឆ្នាំ ក្នុងនោះ ចាប់ផ្តើមពីឆ្នាំ២០២៥ ដល់ឆ្នាំ២០៤៨
-អត្រាការប្រាក់៖ ១% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលអនុគ្រោះ និង១,៥% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលបន្ទាប់

## គ- ស្ថានភាពឥណទានសម្បទានសរុប

### គ.១ ការចុះកិច្ចព្រមព្រៀងឥណទានសម្បទាន

គិតចាប់ពីឆ្នាំ១៩៩៣ រហូតមកទល់នឹងដំណាច់ឆមាសទីពីរ ឆ្នាំ២០១៦ នេះ (ដោយមិនគិតបំណុលចាស់ ឬ បំណុលជាមរតកកំពុងដោះស្រាយ) រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងខ្ចីឥណទានសម្បទានជាមួយដៃគូអភិវឌ្ឍន៍នានាសរុបចំនួនប្រមាណ *៨ ៣០៩,៨១ លានដុល្លារអាមេរិក* ក្នុងនោះ ជាមួយរដ្ឋាភិបាលបរទេស (សាធារណរដ្ឋប្រជាមានិតចិន, សាធារណរដ្ឋបារាំង, សាធារណរដ្ឋឥណ្ឌា, សាធារណរដ្ឋកូរ៉េ, ជប៉ុន, ម៉ាឡេស៊ី, ព្រះរាជាណាចក្រថៃ, និងសាធារណរដ្ឋសង្គមនិយមវៀតណាម) មានចំនួនប្រមាណ *៥ ៣៤៧,៤៩ លានដុល្លារអាមេរិក* (ស្មើនឹងប្រមាណ ៦៤,៣៥% នៃទំហំឥណទានសម្បទានសរុប) និងជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី (ADB, WB, IFAD, NDF, និង OFID) មា នប្រមាណ *២ ៩៦២,៣២ លានដុល្លារអាមេរិក* (ស្មើនឹងប្រមាណ ៣៥,៦៥% នៃទំហំឥណទានសម្បទានសរុប)។

*សូមបញ្ជាក់ជូនថា តួលេខនៃការចុះកិច្ចព្រមព្រៀងឥណទានសម្បទាននេះ ពុំមែនជាតួលេខសន្និធិបំណុលទេ ហើយការខ្ចីឥណទានសម្បទានទាំងនេះ គឺមានអនុលោមភាពនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ព្រមទាំងស្របតាមឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។*

### គ.២ ការដកសាច់ប្រាក់

នៅក្នុងឆមាសទី២ ឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបប្រមាណ ***២៩៧,៩៧ លានដុល្លារអាមេរិក*** ក្នុងនោះ៖ ក្របខ័ណ្ឌទ្វេភាគី មានចំនួនប្រមាណ ***១៩១,៥៦ លានដុល្លារអាមេរិក*** និងក្របខ័ណ្ឌពហុភាគី មានចំនួនប្រមាណ ***១០៦,៤១ លានដុល្លារអាមេរិក***។

បើគិតជាតួលេខសរុបប្រចាំឆ្នាំ នៅក្នុងឆ្នាំ២០១៦ នេះ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបប្រមាណ ***៥៣៦,៥៤ លានដុល្លារអាមេរិក*** ក្នុងនោះ៖ ក្របខ័ណ្ឌទ្វេភាគី មានចំនួនប្រមាណ ***៣៧៦,៩៦ លានដុល្លារអាមេរិក*** និងក្របខ័ណ្ឌពហុភាគី មានចំនួនប្រមាណ ***១៥៩,៥៨ លានដុល្លារអាមេរិក***។

ដោយឡែក បើគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដកសាច់ប្រាក់ពីដៃគូអភិវឌ្ឍន៍យកមកប្រើប្រាស់ជាក់ស្តែងសរុបប្រមាណ *៦ ១២២,៩២ លានដុល្លារអាមេរិក* ស្មើនឹងប្រមាណ ៧៣,៦៨% នៃទំហំឥណទានសម្បទានសរុបដែលបានចុះកិច្ចព្រមព្រៀងខាងលើ ក្នុងនោះ៖ ក្របខ័ណ្ឌទ្វេភាគីមានចំនួនប្រមាណ *៤ ០៤៨,៧៤ លានដុល្លារអាមេរិក* និងក្របខ័ណ្ឌពហុភាគីមានចំនួនប្រមាណ *២ ០៧៤,១៨ លានដុល្លារអាមេរិក*។

គ.៣ សន្និធិបំណុល

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ *៦ ២០៣,០៩ លានដុល្លារអាមេរិក* ក្នុងនោះចំនួនប្រមាណ *៦ ១៩៩,៧០ លានដុល្លារអាមេរិក* (៩៩,៩៥%) ជាបំណុលសាធារណៈក្រៅប្រទេស និងចំនួនប្រមាណ *៣,៣៩ លានដុល្លារអាមេរិក* (0,0៥%) ទៀត ជាបំណុលសាធារណៈក្នុងប្រទេស។

សន្និធិបំណុលសាធារណៈក្រៅប្រទេស គឺស្មើនឹង៖ សាច់ប្រាក់ដែលបានដក (Disbursement) ចំនួន *៦ ១២២,៩២ លានដុល្លារអាមេរិក* - បំណុលដែលបានលុបដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ចំនួន *៩០,៦៤ លានដុល្លារអាមេរិក* - សាច់ប្រាក់ដែលបានបង្វែរទៅដៃគូអភិវឌ្ឍន៍វិញ (Refund to Creditors) ចំនួន *៨,០៤ លានដុល្លារអាមេរិក* + សន្និធិបំណុលដែលបានរៀបចំកម្មវិធីសងឡើងវិញ (Rescheduled Debts) ចំនួន *២៧,៩៦ លានដុល្លារអាមេរិក* + បំណុលចាស់ (Old Debts) ឬបំណុលមរតកកំពុងដោះស្រាយចំនួន *៦២០.០៥ លានដុល្លារអាមេរិក* (សហរដ្ឋអាមេរិកចំនួនប្រមាណ ១៦២,២៧ លានដុល្លារអាមេរិក និងរុស្ស៊ីចំនួនប្រមាណ ៤៥៧,៧៨ លានដុល្លារអាមេរិក) - ប្រាក់ដើមដែលបានសងទៅគេវិញ (Principal Repaid) ចំនួន *៤៧២,៥៤ លានដុល្លារអាមេរិក*។

គ.៤ អនុបាតបំណុល

តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ គេអាចវាយតម្លៃស្ថានភាពបំណុលរបស់ប្រទេសមួយបាន ដោយពិនិត្យទៅលើអនុបាតបំណុលសំខាន់ចំនួន ៥ ធៀបនឹងអនុបាតគោល។ តាមការវិភាគ និងព្យាករណ៍បង្ហាញថា អនុបាតបំណុលសំខាន់ៗ ទាំង ៥ របស់កម្ពុជា នៅក្នុងឆ្នាំ២០១៦ *សុទ្ធតែស្ថិតក្រោមអនុបាតគោល* ក្នុងនោះ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផសស ស្ថិតក្នុងកម្រិត ២០,១% (ដោយមិនទាន់គិតបញ្ចូលបំណុលមរតកកំពុងដោះស្រាយ) និងស្ថិតក្នុងកម្រិត **២២,៥%** (ដោយគិតបញ្ចូលបំណុលមរតកកំពុងដោះស្រាយ) ធៀបនឹងអនុបាតគោលកម្រិត ៤០%។

*ក្នុងស្ថានភាពដូចបានជម្រាបខាងលើ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ គឺស្ថានភាពបំណុលសាធារណៈបច្ចុប្បន្ន "មានចីរភាព" និងប្រឈមនូវ "ហានិភ័យកម្រិតទាប" ហើយមូលនិធិរូបិយវត្ថុអន្តរជាតិ "IMF" ក៏បានវាយតម្លៃដូចគ្នានេះដែរ។*